# សិលាចារឹកប្រាសាទអកយំ K.749

ប្រាសាទអកយំ មានទីតាំងស្ថិតនៅខ្នងទំនប់បារាយណ៍ខាងលិច ឬហៅបារាយណ៍ទឹកថ្លា ដែលចាប់ផ្ដើមកសាងឡើងនៅរវាងដើមស.វ.ទី៨ ហើយទំនងមានសាងបន្ថែមនៅសម័យក្រោយទៀត។ អ្នកស្រាវជ្រាវជាច្រើនយល់ថា ប្រាសាទអកយំ អាចជាទម្រង់ប្រាសាទភ្នំដំបូងគេនៅក្នុងសិល្បៈខ្មែរ។ ប្រាសាទនេះ សាងសង់ឡើងនៅលើខឿនខ្ពស់ផុតអំពីដីរាងជាថ្នាក់ៗ ដែលគំនិតនេះលេចឡើងច្បាស់លាស់នៅរចនាបថព្រះគោ (ប្រាសាទបាខែង)។ នៅទីនេះ គេបានរកឃើញសិលាចារឹកចំនួន ៣ ផ្ទាំង ដែលចុះបញ្ជីលេខ K.749, K.752 និង K.753។ នៅក្នុងអត្ថបទនេះ យើងនឹងលើកយកតែសិលាចារឹក K.749 មកពិភាក្សាតែប៉ុណ្ណោះ។ សិលាចារឹកនេះចារឡើងនៅសម័យមុនអង្គរដំណាលពេលជាមួយការសាងសង់ប្រាសាទ។ តើសិលាចារឹកប្រាសាទអកយំ K.749 នេះ មានអត្ថន័យដូចម្ដេចខ្លះ?

សិលាចារឹកប្រាសាទអកយំ K.749 ធ្លាប់សិក្សាដោយលោក ហ្សក សឺដេស ម្ដងរួចមកហើយ ដែលចុះផ្សាយនៅក្នុងសៀវភៅបញ្ជីសិលាចារឹកខ្មែររបស់លោក នៅភាគទី៤។ សិលាចារឹកនេះចារឹកឡើងជាភាសាខ្មែរ មានចំនួន ១៥ បន្ទាត់ ហើយមានកម្ពស់ ០,៦៥ម៉ែត្រ និងទទឹង ០,៤៥ ម៉ែត្រ។ នៅផ្នែកដំបូងរបស់សិលាចារឹកមានរំលេចអំពីកាលបរិច្ឆេទដែលមានលេខបីខ្ទង់ ប៉ុន្តែបាត់មួយលេខខាងដើម នៅសល់តែលេខខាងចុងថា "..៣៩"។ ដូច្នេះ តាមរយៈរូបរាងអក្សរ និងក្បាច់លម្អស្ថាបត្យកម្មរបស់ប្រាសាទ យើងអាចសន្និដ្ឋានថា លេខនៅខាងដើមប្រហែលជាលេខ ៦ ពោល គឺត្រូវនឹងមហាសករាជឆ្នាំ ៦៣៩ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៧១៧ ដែលត្រូវនឹងរជ្ជកាលរបស់ព្រះនាងជ័យទេវី (ស្ដេចស្រីនៅសម័យចេនឡា ដែលជាបុត្រីរបស់ព្រះបាទជ័យវរ្ម័នទី១)។ ក្រៅពីរលុបកាលបរិច្ឆេទនៅខាងមុខ ក៏មានផ្នែកខ្លះនៃសិលាចារឹកបានរលុបអក្សរអស់ច្រើនទៅហើយ ដែលយើងអាចនៅមើលយល់តែផ្នែកខ្លះ និងអត្ថន័យជារួមតែប៉ុណ្ណោះ។ អត្ថន័យជារួមរបស់សិលាចារឹកនេះ គឺរៀបរាប់អំពីកស្តុភារបណ្ណាការជាតង្វាយរបស់ម្រតាញកីត្តិគណ ថ្វាយចំពោះព្រះស្រីគម្ភីរេស្វរ នៅមហាសករាជឆ្នាំ ៦៣៩ ថ្ងៃ១កើត ខែអាសាឍ ថ្ងៃសៅរ៍ ដែលមានដូចជាខ្ញុំបម្រើប្រុសស្រី អង្ករ គោ .... ។ល។

គួរឱ្យកត់សម្គាល់ ទេពដែលគេតម្កល់នៅប្រាសាទអកយំដែលមានព្រះនាមថា "ស្រីគម្ភីរេស្វរ" យើងធ្លាប់ឃើញមាននៅច្រើនកន្លែងនៅស.វ.ទី៧។ ជាក់ស្ដែង សិលាចារឹកមួយរកឃើញនៅប្រាសាទក្បាលជ្រូកក្នុងតំបន់ប្រាសាទសំបូរព្រៃគុក ក៏បានបង្ហាញអំពីលិង្គមួយមានព្រះនាមនេះ

អត្ថបទដោយ៖ កំ វណ្ណាវ៉ា

*ដែរ ដែលសិវលិង្គនោះសាងឡើងដោយព្រះបាទជ័យវរ្ម័នទី១ (គ.ស.៦៥៧ - ៦៨១)។ ក្រៅពីនេះក៏ធ្លាប់ឃើញនៅសិលាចារឹកប្រាសាទគោករកាផងដែរ។*

## អត្ថបទពាក្យចារឹក

១. x៣៩ ឝកបរិក្រហ

២. មោយ កោតិ អាមាដ ឝនៃគក្ខរវារ បុរ្វ្វសុឝក្ស

៣. ត្រ ឆ្នុ ម្រតាញ់ គីត្តិគណ កល្បិត សត្រ អាយ ព្រះកំ

៤. ម្រតាឝ៏ អញ ត្រីគម្ភីរេឝ្វរ // ជ្នះ តកាង្តែ / តៃ

៥. ក.ល ............រង្កោ..លិះ // ត្មុរ ប

៦. ញ្ញ រទេះ // ត្មុរិ ...................១ ចង្កេកិ

៧. ...........................................ម្រតាញ

៨. គីត្តិគណ តាញ ទ្រ..យ្យ៍ ជ្នះ ...ណ្វា...យ្យ៍.អន្ទ្រាក្ក ជ្នះ

៩. ក...តិ ត រក្សា នេះ កល្បិត ម្រតាញ គីត្តិគណ អា

១០. យិ ត ព្រះកំម្រតាឝ៏ អញ ត្រីគម្ភីរេឝ្វរ //

១១. ក្ញុំ ម្រតាញ គីត្តិគណ មនិ ឱយ ត កេ ក្វនិ ឆ្នុ កេ បម្រេ អាយតព្រះកំម្រតាឝ៏ អ

១២. ញ ត្រីគម្ភីរេឝ្វរ មនិ ឱយ ត ហរិគណ ក្ញុំ តៃ កុ អ្មេ លំវង៍ ១ កុ .....វា

១៣. កន្ទ្រោយ ១ មន ឱយ តហរិវាហន យោ វា ស្រច ត ភាគ្យ ១ មន ឱយ ត តាញ

១៤. គាយិ ក្ញុំ តៃ ប្រតោន ១ នេះ ឧចាយ ឆ្នុ កេ ក្វន ម្រតាញ គីត្តិគណ បំ

១៥. ម្រេ ញ្ញ ត ព្រះកំម្រតាឝ៏ អញ ត្រីគម្ភីរេឝ្វរ //

## បំណកប្រែ

*(១-១០) នៅឆ្នាំ x៣៩ នៃមហាសករាជ ១កើត ខែអាសាឍ ថ្ងៃសៅរ៍ បុរ្វសុនក្សត្រម្រតាញ កីត្តិគណ បានថ្វាយតង្វាយដល់ព្រះស្រីគម្ភីរេស្វរ។ តង្វាយមានអ្នកបម្រើនារីមានឈ្មោះ តៃ ក.ល ........អង្គរ..លិះ, រទេះគោ, គោ (ត្មុរិ) ...១សម្លៀកបំពាក់ .....ម្រតាញ កីត្តិគណ, តាញ ........ឈ្មោះ ...អន្ទ្រាក្ក ឈ្មោ...អ្នកដែលថែរក្សា នូវគ្រឿងកស្តុភារតង្វាយរបស់ម្រតាញកីត្តិគណ ដែលបានថ្វាយដល់ព្រះស្រីគម្ភីរេស្វរ ។*

*(១១-១៥) ខ្ញុំបម្រើរបស់ម្រតាញកីត្តិគណ ដែលបានថ្វាយអ្នកបម្រើ កូន ថ្វាយចំពោះព្រះស្រីគម្ភីរេស្វរ ។ អ្នកបម្រើនារីថ្វាយចំពោះព្រះហរិគណ មាន៖ កុអ្មេ លំវង៍១ កុ...វាកន្ទ្រោយ ១។ អ្នកបម្រើបុរស ដែលបានថ្វាយចំពោះព្រះហរិវាហន មាន៖ វាស្រចតភាគ្យ ១។ ថ្វាយដោយតាញគាយ*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

មាន៖ អ្នកបម្រើនារីឈ្មោះ តែប្រតោន១ នេះជាឧបាយ (សម្រាប់ឧបត្ថម្ភ) និងកូនម្រតាញកីត្តិគណ ដែលបម្រើចំពោះព្រះស្រីគម្ភីរេស្វរ។

ជារួមមក សិលាចារឹកប្រាសាទអកយំ K.749 បានឱ្យយើងដឹងអំពីព្រឹត្តិការណ៍ខ្វះនៅក្នុងរជ្ជកាលព្រះនាងជ័យទេវី ហើយក៏អាចយល់បានខ្វះពីព្រឹត្តិការណ៍របស់បិតារបស់ព្រះនាង គឺព្រះបាទជ័យវរ្ម័នទី១។ ដូចដែលអ្នកប្រវត្តិវិទូធ្លាប់លើកឡើងហើយថា នៅរជ្ជកាលព្រះនាងជ័យទេវីមានសិលាចារឹកតិចតួចបំផុត។ លើសពីនេះ យើងអាចដឹងអំពីកាលបរិច្ឆេទនៃការសាងសង់ប្រាសាទអកយំនៅដំណាក់កាលដំបូង ដែលប្រហែលសង់ឡើងនៅក្នុងរជ្ជកាលព្រះនាងជ័យទេវីក្នុងគ.ស.៧១៧៕

## ឯកសារយោង

Coedès, G. 1937-1966. *Inscription du Camdodge,* 8 Volumes, Hanoi.



រូបលេខ១៖ ប្រាសាទអកយំ (រូបថត៖ ម៉ង់ វ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ២៤៖ ប្រាសាទអកយំ (រូបថត៖ ម៉េង វ៉ាលី)



រូបលេខ៣៖ ប្រាសាទអកយំ (រូបថត៖ ម៉េង វ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណាវ៉ា




រូបលេខ២៤៖ ក្រដាសផ្តិតសិលាចារឹកប្រាសាទអកយំ K.749 (ផ្តិតដោយ៖ កំ វណ្ណារ៉ា)